**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ......៩៩៥......សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៧

# ប្រកាសរួម
# ស្តីពី
# ការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- សារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- តាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១** :

អនុញ្ញាតឱ្យក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ។

កម្រងសេវាសាធារណៈនេះ មានបញ្ជាក់លម្អិតអំពីតម្លៃសេវា រយៈពេលផ្តល់សេវា និងសុពលភាព ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយនឹងប្រកាសរួមនេះ។

**ប្រការ ២** :

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបិទផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវា នូវស្តង់ដារសេវា ក្នុងនោះរួមមាន ៖ តារាងតម្លៃ ទម្រង់ឯកសារ និងនីតិវិធីសម្រាប់ការផ្តល់សេវា ពាក់ព័ន្ធនឹងការប្រមូលចំណូលខាងលើនេះ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងដោយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬមានការយកកម្រៃលើសការកំណត់ ឬមានការយឺតយ៉ាវ ជាដើម។

**ប្រការ ៣** :

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានភារកិច្ចប្រមូលចំណូល ទទួលខុសត្រូវប្រាក់ចំណូលដែលប្រមូលបាន និងបង់ប្រាក់ចំណូលចូលថវិកាជាតិ ក្នុងនោះ ត្រូវចុះកិច្ចបញ្ជិកាគណនេយ្យ ស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាថវិកា ព្រមទាំងធ្វើសលាកប័ត្រចំណូល។

**ប្រការ ៤** :

ការបែងចែកភារកិច្ចលើការគ្រប់គ្រង ការប្រមូលចំណូល ពីការផ្តល់សេវាសាធារណៈ រវាងរដ្ឋបាលកណ្តាល នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវផ្ញើសេចក្តីប្រកាសនេះចំនួនមួយច្បាប់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជូនជ្រាបជាព័ត៌មាន និងសម្រាប់តាមដានការអនុវត្តចំណូល។

**ប្រការ ៥** :

រាល់ការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយប្រកាសរួមនេះ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលបានបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៦** :

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ទីតាំងដាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយ នៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា តាមការកំណត់។

**ប្រការ ៧** :

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវធ្វើរបាយការណ៍ ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ដើម្បីផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ ៨** :

កម្រងសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសរួមនេះ អាចកែប្រែបាន តាមការចាំបាច់តាមរយៈប្រកាសរួម។

**ប្រការ ៩** :

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១០ :**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ពាន យន់**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**អ៊ឹម ឈុនលឹម**

ចម្លងជូន:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសេវាកម្មជាតិ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
«ដើម្បីជូនជ្រាប»
- ដូចប្រការ ១០ «ដើម្បីអនុវត្ត»
- ឯកសារ - កាលប្បវត្តិ

# តារាងឧបសម្ព័ន្ធ

## ភ្ជាប់នឹងប្រកាសរួមលេខ ៩៩៥ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២

## ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

| ល.រ | បរិយាយ | តម្លៃសេវា (ជារៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| I - សេវាសុរិយោដី និងភូមិសាស្ត្រ | | | | | |
| 1 | ការចុះបញ្ជីលើកដំបូង ដែលមានលក្ខណៈជាប្រព័ន្ធ (ក្នុង 1ម$^2$) | | | គ្មានអាជ្ញាយុកាល | |
| 1.1 | ដីផលិតកម្មកសិកម្មជនបទ | 1 | 100-140ថ្ងៃ | | (100រៀលសម្រាប់ដីតូចជាង 100ម$^2$) |
| 1.2 | ដីលំនៅដ្ឋានជនបទ | 10 | 100-140ថ្ងៃ | | |
| 1.3 | ដីលំនៅដ្ឋានទីប្រជុំជនស្រុក ឬជាយទីប្រជុំជនខេត្ត | 20 | 100-140ថ្ងៃ | | |
| 1.4 | ដីលំនៅដ្ឋានទីប្រជុំជនខេត្ត ឬជាយទីប្រជុំជនរាជធានីភ្នំពេញ | 250 | 100-140ថ្ងៃ | | |
| 1.5 | ដីលំនៅដ្ឋានទីប្រជុំជនរាជធានីភ្នំពេញ | 500 | 100-140ថ្ងៃ | | |
| 2 | ការចុះបញ្ជីដីលើកដំបូងមានលក្ខណៈដាច់ដោយដុំ និងចេញប័ណ្ណ (ក្នុង 1ក្បាលដី) | | | គ្មានអាជ្ញាយុកាល | |
| 2.1 | ដីផលិតកម្ម ឬដីភោគៈ គ្រប់ខេត្ត និងរាជធានី | 200,000 | 75ថ្ងៃ | | ករណីធំជាង 5 ហិចតា បន្ថែម 40,000រៀល ក្នុង 1 ហិចតា |

| ល.រ | បរិយាយ | តម្លៃសេវា (ជារៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| 2.2 | ដីលំនៅដ្ឋាន និងដីសម្រាប់សំណង់ទូទៅ | | | | |
| | - ដីក្នុងរាជធានីភ្នំពេញ ឬក្នុងក្រុងខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 400,000 | 75ថ្ងៃ | | ករណីធំជាង 1 ហិចតា បន្ថែម 80,000រៀល ក្នុង 1ហិចតា |
| | - ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 300,000 | 75ថ្ងៃ | | ករណីធំជាង 1 ហិចតា បន្ថែម 60,000រៀល ក្នុង 1ហិចតា |
| | - ដីជនបទ ឬក្រៅក្រុង | 100,000 | 75ថ្ងៃ | | ករណីធំជាង 1 ហិចតា បន្ថែម 30,000រៀល ក្នុង 1ហិចតា |
| 2.3 | ការចេញប័ណ្ណទុតិយតា ឬតតិយតា | | | | |
| | - សម្រាប់ដីលំនៅដ្ឋាន | 400,000 | 60-70ថ្ងៃ | | |
| | - សម្រាប់ដីផលិតកម្ម ឬដីភោគៈ | 300,000 | 60-70ថ្ងៃ | | |
| 3 | ការផ្ទេរអចលនវត្ថុទាំងមូល (ក្នុង 1ប័ណ្ណ) | | | | |
| 3.1 | ដីផលិតកម្ម ឬដីភោគៈ គ្រប់ខេត្ត និងរាជធានី | 200,000 | 15-20ថ្ងៃ | | |

| ល.រ | បរិយាយ | តម្លៃសេវា (ជារៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| 3.2 | ដីលំនៅដ្ឋាន និងដីសម្រាប់សំណង់ទូទៅ | | | | |
| | - ដីក្នុងរាជធានី ឬក្នុងក្រុងខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 600,000 | 15-20ថ្ងៃ | | |
| | - ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 400,000 | 15-20ថ្ងៃ | | |
| | - ដីជនបទ ឬក្រៅក្រុង | 200,000 | 15-20ថ្ងៃ | | |
| 4 | ការបំបែកក្បាលដីដោយផ្ទេរ ឬដោយមិនផ្ទេរអចលនវត្ថុ (ក្នុង 1ក្បាលដីដែលបំបែក) និងការបង្រួមក្បាលដី (ក្នុង 1ក្បាលដីដើម) (តាមការស្នើសុំ) | | | | |
| 4.1 | ដីផលិតកម្ម ឬដីភោគៈ គ្រប់ខេត្ត និងរាជធានី | 200,000 | 30ថ្ងៃ | | ករណីបំបែក ឬបង្រួមលើសពី 2ក្បាលដី បន្ថែម 40,000រៀល ក្នុង 1 ក្បាលដី |
| 4.2 | ដីលំនៅដ្ឋាន និងដីសម្រាប់សំណង់ទូទៅ | | | | |
| | - ដីក្នុងរាជធានី ឬក្នុងក្រុងខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 600,000 | 30ថ្ងៃ | | ករណីបំបែក ឬបង្រួមលើសពី 2ក្បាលដី បន្ថែម 80,000រៀល ក្នុង 1ក្បាលដី |

| ល.រ | បរិយាយ | តម្លៃសេវា (ជារៀល) | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្ដីផ្សេងៗ |
|---|---|---|---|---|---|
| | - ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 400,000 | 30ថ្ងៃ | | ករណីបំបែក ឬ បង្រួមលើសពី 2ក្បាលដី បន្ថែម 60,000រៀល ក្នុង 1ក្បាលដី |
| | - ដីជនបទ ឬក្រៅក្រុង | 100,000 | 30ថ្ងៃ | | ករណីបំបែក ឬ បង្រួមលើសពី 2ក្បាលដី បន្ថែម 30,000រៀល ក្នុង 1ក្បាលដី |
| 5 | ការស្វែងរកចំណុចព្រំដីឡើងវិញ (ក្នុង 1បង្គោល) | | | | |
| 5.1 | ដីផលិតកម្ម ឬដីភោគៈ គ្រប់ខេត្ត និងរាជធានី | 30,000 | 5-10ថ្ងៃ | | |
| 5.2 | ដីលំនៅដ្ឋាន និងដីសម្រាប់សំណង់ទូទៅ | | | | |
| | - ដីក្នុងរាជធានី ឬក្នុងក្រុងខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 60,000 | 5-10ថ្ងៃ | | |
| | - ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 40,000 | 5-10ថ្ងៃ | | |
| | - ដីជនបទ ឬក្រៅក្រុង | 30,000 | 5-10ថ្ងៃ | | |

| ល.រ | បរិយាយ | តម្លៃសេវា (ជារៀល) | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្ដីផ្សេងៗ |
|---|---|---|---|---|---|
| 6 | ការចេញលិខិតបញ្ជាក់ព័ត៌មានសុរិយោដី ក្នុង 1ក្បាលដី (ការចេញលិខិតបញ្ជាក់ ការចេញសលាកប័ត្រព័ត៌មាន ការចេញលិខិតបញ្ជាក់សុរិយោដី) | 50,000 | 03-05ថ្ងៃ | 1ខែ | |
| 7 | ការដាក់បន្ទុក និងការលើកលែង ៖ ឯកសិទ្ធិ ការដាក់បញ្ចាំ និងការដាក់ហ៊ីប៉ូតែក (ក្នុង 1ក្បាលដី ឬ 1ប័ណ្ណ) | | | | |
| 7.1 | ការដាក់បន្ទុក(ឯកសិទ្ធិ ការដាក់បញ្ចាំ និងការដាក់ហ៊ីប៉ូតែក) | 200,000 | 03-05ថ្ងៃ | | |
| 7.2 | ការលើកលែងបន្ទុក (ឯកសិទ្ធិ ការដាក់បញ្ចាំ និងការដាក់ហ៊ីប៉ូតែក) | 100,000 | 02-03ថ្ងៃ | | |
| 8 | ការថតចម្លងឯកសារសុរិយោដី (ក្នុង 1ទំព័រក្រដាស A4 ) | 5,000 | 02-03ថ្ងៃ | | |
| 9 | ការប្ដូរប្រភេទដី (ក្នុង 1ម$^2$) | 50 | 20-25ថ្ងៃ | | |
| 10 | ការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ (ក្នុង 1ចំណែកឯកជន) | | | | |
| | - ការចុះបញ្ជី និងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជនទូទៅ ឬវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍នៃចំណែកឯកជនទូទៅ | 1,600,000 | 50-60ថ្ងៃ | | |
| | - ការចុះបញ្ជីផ្ទេរសិទ្ធិលើចំណែកឯកជនទូទៅ | 1,200,000 | 20ថ្ងៃ | | |
| | - ការចុះបញ្ជី និងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជនសម្រាប់អគារសហកម្មសិទ្ធដែលរដ្ឋ, សប្បុរសជន ឬអង្គការមនុស្សធម៌នានាផ្តល់ឱ្យ | 100,000 | 50-60ថ្ងៃ | | |
| | - ការចុះបញ្ជីផ្ទេរសិទ្ធិលើចំណែកឯកជនសម្រាប់អគារសហកម្មសិទ្ធដែលរដ្ឋ, សប្បុរសជន ឬអង្គការមនុស្សធម៌នានាផ្តល់ឱ្យ | 200,000 | 20ថ្ងៃ | | |

| ល.រ | បរិយាយ | តម្លៃសេវា (ជារៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| 11 | ការចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ (ក្នុង 1ប័ណ្ណ) | | | | |
| | - ការចុះបញ្ជី និងចេញប័ណ្ណវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ | 400,000 | 15-20ថ្ងៃ | អាស្រ័យលើកិច្ចសន្យា | ករណីធំជាង 5ហិចតា បន្ថែម 4,000រៀល ក្នុង 1ហិចតា |
| | - ចុះបញ្ជីផ្ទេរសិទ្ធិជួលអចិន្ត្រៃយ៍ | 400,000 | 15-20ថ្ងៃ | | ករណីធំជាង 5ហិចតា បន្ថែម 4,000រៀល ក្នុង 1ហិចតា |
| 12 | ការចុះបញ្ជីសិទ្ធិសម្បទានដីសេដ្ឋកិច្ច (ក្នុង 1ប័ណ្ណ) | | | | |
| | - ការចុះបញ្ជី និងចេញវិញ្ញាបនបត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច | 400,000 | 15-20ថ្ងៃ | អាស្រ័យកិច្ចសន្យា | ករណីធំជាង 5ហិចតា បន្ថែម 4,000រៀល ក្នុង 1ហិចតា |
| | - ចុះបញ្ជីផ្ទេរសិទ្ធិសម្បទានដីសេដ្ឋកិច្ច | 400,000 | 15-20ថ្ងៃ | | ករណីធំជាង 5ហិចតា បន្ថែម 4,000រៀល ក្នុង 1ហិចតា |

| ល.រ | បរិយាយ | តម្លៃសេវា (ជារៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| 13 | ការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី (ក្នុង 1ប័ណ្ណ) | | | | អាស្រ័យនីតិវិធីរបស់តុលាការ |
| 13.1 | ការចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ (ការរឹបអូសកម្មសិទ្ធិ ឬសិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគ) | 120,000 | 03-05ថ្ងៃ | | |
| 13.2 | ការចុះបញ្ជីអំពីការលុបការរឹបអូសអចលនវត្ថុ (ការរឹបអូសកម្មសិទ្ធិ ឬសិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគ) | 80,000 | 03-05ថ្ងៃ | | |
| 13.3 | ការចុះបញ្ជីអំពីការផ្ទេរសិទ្ធិ ការលុបការចុះបញ្ជីអំពីលទ្ធកម្មនូវសិទ្ធិ ការលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ការលុបការចុះបញ្ជីអំពីការរឹបអូស ឬការរឹបអូសជាបណ្តោះអាសន្ន | | | | |
| 13.3.1 | ដីផលិតកម្ម ឬដីភោគៈ គ្រប់ខេត្ត និងរាជធានី | 120,000 | 15-20 ថ្ងៃ | | |
| 13.3.2 | ដីលំនៅដ្ឋាន និងដីសម្រាប់សំណង់ទូទៅ | | | | |
| | - ដីក្នុងរាជធានី ឬក្នុងក្រុងខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 200,000 | 15-20 ថ្ងៃ | | |
| | - ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | 150,000 | 15-20 ថ្ងៃ | | |
| | - ដីជនបទ ឬក្រៅក្រុង | 100,000 | 15-20 ថ្ងៃ | | |

| ល.រ | បរិយាយ | តម្លៃសេវា (ជារៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| 13.4 | ការចុះបញ្ជី(ក្នុង 1ប័ណ្ណ) អំពី:<br>1.ការរឹបអូសចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត<br>2.ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ (កម្មសិទ្ធិ ឬសិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគ)<br>3.ការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិ លើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត<br>4.ការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ (កម្មសិទ្ធិ ឬសិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគ) | 120,000 | 03-05ថ្ងៃ | | |
| 13.5 | ការលុបការចុះបញ្ជី(ក្នុង 1ប័ណ្ណ) អំពី:<br>1.ការរឹបអូសចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត<br>2.ការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ (កម្មសិទ្ធិ ឬសិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគ)<br>3.ការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិ លើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត<br>4.ការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ (កម្មសិទ្ធិ ឬសិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគ) | 80,000 | 03-05ថ្ងៃ | | |

| ល.រ | បរិយាយ | តម្លៃសេវា (ជារៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| 13.6 | -ការចុះបញ្ជីអំពីការបង្កើត ឬការកែប្រែ ឬការលុបនូវសិទ្ធិ តាមសាលក្រម ឬសាលដីកា ឬដីកាសម្រេច ឬលិខិតអនុវត្តដោយផ្អែកលើការផ្សះផ្សា ឬការទទួលស្គាល់នូវការទាមទារ | 120,000 | 15-20ថ្ងៃ | | |
| 14 | ផែនទីជាក្រដាស (ក្នុង 1សន្លឹក) | | | | |
| 14.1 | ផែនទីឋានលេខាមាត្រដ្ឋាន 1/100,000 ដែលមានស្រាប់ | 40,000 | 02-03ថ្ងៃ | | |
| 14.2 | សេវាបោះពុម្ពផែនទីរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជា មាត្រដ្ឋាន 1/650,000 | 40,000 | 02-03ថ្ងៃ | | |
| 15 | រូបថតអ័រតូហ្វូតូ ទំរង់ជាឌីជីថល (ក្នុង 1គ.ម$^2$) | | | | |
| 15.1 | អង្គភាពរដ្ឋដែលស្នើទិញ សម្រាប់តំបន់ជនបទ និងព្រៃ | 20,000 | 02-03ថ្ងៃ | | |
| 15.2 | អង្គភាពរដ្ឋដែលស្នើទិញ សម្រាប់តំបន់ទីប្រជុំជន និងទីក្រុង | 40,000 | 02-03ថ្ងៃ | | |
| 15.3 | ឯកជនដែលស្នើទិញ សម្រាប់តំបន់ជនបទ និងព្រៃ | 80,000 | 02-03ថ្ងៃ | | |
| 15.4 | ឯកជនដែលស្នើទិញ សម្រាប់តំបន់ទីប្រជុំជន និងទីក្រុង | 200,000 | 02-03ថ្ងៃ | | |
| 16 | រូបថតអ័រតូហ្វូតូទំរង់ជាក្រដាស(បោះពុម្ពជាក្រដាសខ្នាតA0) ក្នុង01សន្លឹក | 50,000 | 02-03ថ្ងៃ | | |
| 17 | ទិន្នន័យបង្គោលប្រថពីវិភាគ(ប្លង់ទីតាំង និងនិយាមកា) គិតក្នុង 01 បង្គោល(តាមការស្នើសុំ) | | | | |
| 17.1 | ទិន្នន័យបង្គោលប្រថពីវិភាគថ្នាក់ជាតិលំដាប់សូន្យ | 60,000 | 02-03ថ្ងៃ | | |
| 17.2 | ទិន្នន័យបង្គោលប្រថពីវិភាគថ្នាក់ជាតិលំដាប់ទី1 | 60,000 | 02-03ថ្ងៃ | | |
| 17.3 | ទិន្នន័យបង្គោលប្រថពីវិភាគថ្នាក់ជាតិលំដាប់ទី2 | 50,000 | 02-03ថ្ងៃ | | |
| 17.4 | ទិន្នន័យបង្គោលប្រថពីវិភាគថ្នាក់ជាតិលំដាប់ទី3 | 40,000 | 02-03ថ្ងៃ | | |

| ល.រ | បរិយាយ | តម្លៃសេវា (ជារៀល) | | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|
| 17.5 | ទិន្នន័យបង្គោលពហុកោណគោល | 30,000 | | 02-03ថ្ងៃ | | |
| **II - សេវាសំណង់** | | | | | | |
| **II-1- លិខិតអនុញ្ញាតដែលជាសមត្ថកិច្ចរបស់សាលារាជធានី - ខេត្ត** | | **ក្នុងរាជធានី និងក្នុងក្រុង** | **ក្រៅក្រុង** | | | ក្នុងករណីមិនចាប់ផ្តើមសាងសង់ គឺមានសុពលភាព 1ឆ្នាំ និងអាចសុំបន្តបាន 1ដង |
| 1 | សំណង់លំនៅដ្ឋាន | | | | | |
| 1.1 | លិខិតអនុញ្ញាតសាងសង់ | | | | | |
| 1.1.1 | ភូមិគ្រឹះ (ម$^2$) | | | | | |
| | ≤100 | 600,000 | 420,000 | 25ថ្ងៃ | | |
| | ≤200 | 800,000 | 560,000 | 25ថ្ងៃ | | |
| | ≤300 | 1,000,000 | 700,000 | 25ថ្ងៃ | | |
| | ≤400 | 1,400,000 | 980,000 | 25ថ្ងៃ | | |
| | ≤500 | 1,800,000 | 1,260,000 | 25ថ្ងៃ | | |
| | ≤1000 | 3,500,000 | 2,450,000 | 25ថ្ងៃ | | |
| | ≤2000 | 5,000,000 | 3,500,000 | 25ថ្ងៃ | | |
| | ≤3000 | 7,000,000 | 4,900,000 | 25ថ្ងៃ | | |

| ល.រ | បរិយាយ | តម្លៃសេវា (ជារៀល) | | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|
| 1.1.2 | ផ្ទះល្វែង (ម$^2$) | | | | | |
| | ≤100 | 400,000 | 280,000 | 25ថ្ងៃ | | |
| | ≤200 | 500,000 | 350,000 | 25ថ្ងៃ | | |
| | ≤300 | 600,000 | 420,000 | 25ថ្ងៃ | | |
| | ≤400 | 800,000 | 560,000 | 25ថ្ងៃ | | |
| | ≤500 | 1,200,000 | 840,000 | 25ថ្ងៃ | | |
| | ≤1000 | 2,500,000 | 1,750,000 | 25ថ្ងៃ | | |
| | ≤2000 | 4,000,000 | 2,800,000 | 25ថ្ងៃ | | |
| | ≤3000 | 6,000,000 | 4,200,000 | 25ថ្ងៃ | | |
| 1.1.3 | ផ្ទះថ្មក្រោមឈើលើ (ម$^2$) | | | | | |
| | ≤100 | 140,000 | 98,000 | 25ថ្ងៃ | | |
| | ≤200 | 160,000 | 112,000 | 25ថ្ងៃ | | |
| | ≤300 | 180,000 | 126,000 | 25ថ្ងៃ | | |
| | ≤400 | 200,000 | 140,000 | 25ថ្ងៃ | | |
| | ≤500 | 220,000 | 154,000 | 25ថ្ងៃ | | |
| | ≤1000 | 400,000 | 280,000 | 25ថ្ងៃ | | |
| | ≤2000 | 500,000 | 350,000 | 25ថ្ងៃ | | |
| | ≤3000 | 700,000 | 490,000 | 25ថ្ងៃ | | |

| ល.រ | បរិយាយ | តម្លៃសេវា (ជារៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| 1.2 | លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែមរះរើជួសជុល | គិតទំហំតាម ម$^2$ ដែលត្រូវសាងសង់ពង្រីកបន្ថែម រុះរើជួសជុល និងគិត 10% នៃតម្លៃសុំលិខិតអនុញ្ញាតសាងសង់ | 20ថ្ងៃ | | |
| 1.3 | លិខិតអនុញ្ញាតបើកការដ្ឋាន | គិត 10% នៃតម្លៃសុំលិខិតអនុញ្ញាតសាងសង់ | 07ថ្ងៃ | | |
| 1.4 | លិខិតបិទការដ្ឋាន ឬវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ | គិត 10% នៃតម្លៃសុំលិខិតអនុញ្ញាតសាងសង់ | 07ថ្ងៃ | | |
| 2 | សំណង់អគារផ្សេងៗក្រៅពីលំនៅឋាន | | | | |
| 2.1 | លិខិតអនុញ្ញាតសាងសង់ (ម$^2$) | | | | |
| | ≤100 | 1,000,000 | 25ថ្ងៃ | | |
| | ≤200 | 2,000,000 | 25ថ្ងៃ | | |
| | ≤300 | 3,000,000 | 25ថ្ងៃ | | |
| | ≤400 | 4,000,000 | 25ថ្ងៃ | | |
| | ≤500 | 5,000,000 | 25ថ្ងៃ | | |
| | ≤1000 | 8,000,000 | 25ថ្ងៃ | | |
| | ≤2000 | 10,000,000 | 25ថ្ងៃ | | |

| ល.រ | បរិយាយ | តម្លៃសេវា (ជារៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| | ≤[illegible]000 | 12,000,000 | 25ថ្ងៃ | | |
| 2.2 | លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែមរុះរើជួសជុល | គិតទំហំតាម ម² ដែលត្រូវសាងសង់ពង្រីកបន្ថែមរុះរើជួសជុល និងគិត 10% នៃតម្លៃសុំលិខិតអនុញ្ញាតសាងសង់ | 20ថ្ងៃ | | |
| 2.3 | លិខិតអនុញ្ញាតបើកការដ្ឋាន | គិត 10% នៃតម្លៃសុំលិខិតអនុញ្ញាតសាងសង់ | 07ថ្ងៃ | | |
| 2.4 | លិខិតបិទការដ្ឋាន ឬវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ | គិត 10% នៃតម្លៃសុំលិខិតអនុញ្ញាតសាងសង់ | 07ថ្ងៃ | | |
| 3 | សំណង់រដ្ឋ សំណង់សប្បុរសជន ឬអង្គការមនុស្សធម៌ អំណោយជូនសហគមន៍ ឬជនក្រីក្រ (ទំហំ ≤3.000ម²) | | | | |
| 3.1 | លិខិតអនុញ្ញាតសាងសង់ | មិនគិតថ្លៃ | 25ថ្ងៃ | | |
| 3.2 | លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែមរុះរើជួសជុល | មិនគិតថ្លៃ | 20ថ្ងៃ | | |
| 3.3 | លិខិតអនុញ្ញាតបើកការដ្ឋាន | មិនគិតថ្លៃ | 07ថ្ងៃ | | |
| 3.4 | លិខិតបិទការដ្ឋាន ឬវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ | មិនគិតថ្លៃ | 07ថ្ងៃ | | |
| II-2-**លិខិតអនុញ្ញាតដែលជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** | | | | | |
| 4 | សំណង់ឯកជន | | | | |
| 4.1 | លិខិតអនុញ្ញាតសាងសង់ | | | | |

| ល.រ | បរិយាយ | តម្លៃសេវា (ជារៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| 4.1.1 | សំណង់លំនៅឋាន (ម$^2$) | | | | |
| | ≤4000 | 10,000,000 | 45ថ្ងៃ | | |
| | ≤6000 | 10,500,000 | 45ថ្ងៃ | | |
| | ≤10000 | 11,000,000 | 45ថ្ងៃ | | |
| | ≤20000 | 11,200,000 | 45ថ្ងៃ | | |
| | ≤40000 | 11,400,000 | 45ថ្ងៃ | | |
| | ≤60000 | 11,600,000 | 45ថ្ងៃ | | |
| | ≤100000 | 11,800,000 | 45ថ្ងៃ | | |
| | >100000 | 12,000,000 | 45ថ្ងៃ | | |
| 4.1.2 | សំណង់អគារផ្សេងៗក្រៅពីលំនៅឋាន (ម$^2$) | | | | |
| | ≤4000 | 15,000,000 | 45ថ្ងៃ | | |
| | ≤6000 | 16,500,000 | 45ថ្ងៃ | | |
| | ≤10000 | 18,000,000 | 45ថ្ងៃ | | |
| | ≤20000 | 19,500,000 | 45ថ្ងៃ | | |
| | ≤40000 | 19,800,000 | 45ថ្ងៃ | | |
| | ≤60000 | 20,100,000 | 45ថ្ងៃ | | |
| | ≤100000 | 20,400,000 | 45ថ្ងៃ | | |
| | >100000 | 21,000,000 | 45ថ្ងៃ | | |

| ល.រ | បរិយាយ | តម្លៃសេវា (ជារៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| 4.2 | លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែមរុះរើជួសជុល | គិតទំហំតាម ម$^2$ ដែលត្រូវសាងសង់ពង្រីកបន្ថែម រុះរើជួសជុល និងគិត 20% នៃតម្លៃសុំលិខិតអនុញ្ញាតសាងសង់ | 45ថ្ងៃ | | |
| 4.3 | លិខិតអនុញ្ញាតបើកការដ្ឋាន | គិត 20% នៃតម្លៃសុំលិខិតអនុញ្ញាតសាងសង់ | 07ថ្ងៃ | | |
| 4.4 | លិខិតបិទការដ្ឋាន ឬវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ | គិត 20% នៃតម្លៃសុំលិខិតអនុញ្ញាតសាងសង់ | 07ថ្ងៃ | | |
| 5 | សំណង់រដ្ឋ សំណង់សប្បុរសជន ឬអង្គការមនុស្សធម៌ អំណោយជូនសហគម ឬជនក្រីក្រ ( ទំហំ > 3.000ម$^2$) | | | | |
| 5.1 | លិខិតអនុញ្ញាតសាងសង់ | មិនគិតថ្លៃ | 45ថ្ងៃ | | |
| 5.2 | លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែមរុះរើជួសជុល | មិនគិតថ្លៃ | 45ថ្ងៃ | | |
| 5.3 | លិខិតអនុញ្ញាតបើកការដ្ឋាន | មិនគិតថ្លៃ | 07ថ្ងៃ | | |
| 5.4 | លិខិតបិទការដ្ឋាន ឬវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ | មិនគិតថ្លៃ | 07ថ្ងៃ | | |
| II-3 **ការផ្តល់គោលការណ៍សាងសង់ និងអភិវឌ្ឍន៍ដី** | | | | | |
| 6 | សមត្ថកិច្ចរបស់សាលារាជធានី ខេត្ត | | | | |
| 6.1 | ប្តូរឈ្មោះក្នុងលិខិតអនុញ្ញាតសាងសង់ និងក្នុងប្លង់ស្ថាបត្យកម្ម | 1,000,000 | 25ថ្ងៃ | | |

| ល.រ | បរិយាយ | តម្លៃសេវា (ជារៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| 6.2 | បន្តសុពលភាពលិខិតអនុញ្ញាតសាងសង់ (ក្នុងករណីមិនចាប់ផ្តើមសាងសង់ បន្ទាប់ពីបានការអនុញ្ញាតបាន 1 ឆ្នាំ និងក្នុងករណីមិនមានលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់) | គិត 50% នៃតម្លៃសុំលិខិតអនុញ្ញាតសាងសង់ | 25ថ្ងៃ | | |
| 6.3 | បន្តសុពលភាពលិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែមរុះរើជួសជុល (ក្នុងករណីមិនចាប់ផ្តើមជួសជុល បន្ទាប់ពីបានការអនុញ្ញាតបាន 1 ឆ្នាំ) | គិត 20% នៃតម្លៃសុំលិខិតអនុញ្ញាតសាងសង់ | 20ថ្ងៃ | | |
| 7 | សមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | | | |
| 7.1 | ប្តូរឈ្មោះក្នុងលិខិតអនុញ្ញាតសាងសង់ និងក្នុងប្លង់ស្ថាបត្យកម្ម | 4,000,000 | 45ថ្ងៃ | | |
| 7.2 | បន្តសុពលភាពលិខិតអនុញ្ញាតសាងសង់ (ក្នុងករណីមិនចាប់ផ្តើមសាងសង់ បន្ទាប់ពីបានការអនុញ្ញាតបាន 1 ឆ្នាំ និងក្នុងករណីមិនមានលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់) | គិត 50% នៃតម្លៃសុំលិខិតអនុញ្ញាតសាងសង់ | 45ថ្ងៃ | | |
| 7.3 | បន្តសុពលភាពលិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែមរុះរើជួសជុល (ក្នុងករណីមិនចាប់ផ្តើមជួសជុល បន្ទាប់ពីបានការអនុញ្ញាតបាន 1 ឆ្នាំ) | គិត 20% នៃតម្លៃសុំលិខិតអនុញ្ញាតសាងសង់ | 45ថ្ងៃ | | |
| 7.4 | គោលការណ៍សាងសង់អង់តែនក្នុងមួយកន្លែង | 400,000 | 45ថ្ងៃ | | |
| 7.5 | គោលការណ៍សាងសង់អគារក្នុងដីឡូតិ៍ (តាមការស្នើសុំ) | គិត 20% នៃតម្លៃសុំលិខិតអនុញ្ញាតសាងសង់ | 45ថ្ងៃ | | |
| 7.6 | លិខិតអនុញ្ញាតជាគោលការណ៍ ឬលិខិតអនុញ្ញាតអភិវឌ្ឍន៍ដីពីដីកសិកម្ម ទៅដីសាងសង់ (សម្រាប់លំនៅដ្ឋានក្នុងគោលបំណងពាណិជ្ជកម្ម, ពាណិជ្ជកម្ម និងឧស្សាហកម្ម) | | | | |

| ល.រ | បរិយាយ | តម្លៃសេវា (ជារៀល) | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្ដីផ្សេងៗ |
|---|---|---|---|---|---|
| | - ទំហំក្រោម 10 ហិចតា (ក្នុងដី 1ម$^2$) | 200 | 45ថ្ងៃ | | |
| | - ទំហំចាប់ពី 10 ហិចតាឡើង (គិតសរុប) | 20,000,000 | 45ថ្ងៃ | | |
| **III- ការចុះបញ្ជីសហគ្រាស-ក្រុមហ៊ុនប្រកបអាជីវកម្មសំណង់ រូបវន្តបុគ្គលសិក្សាគម្រោងប្លង់ និងក្រុមជាងសំណង់** | | | | | |
| **III-1- ក្នុងសមត្ថកិច្ចរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី - ខេត្ត** | | | | | |
| 1 | ចុះបញ្ជីលើកដំបូងសម្រាប់ក្រុមជាងសំណង់ | 800,000 | 07ថ្ងៃ | 3ឆ្នាំ | |
| 2 | បន្តសុពលភាពសម្រាប់ក្រុមជាងសំណង់ | 600,000 | 07ថ្ងៃ | 3ឆ្នាំ | |
| **III-2- ក្នុងសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** | | | | | |
| 1 | ចុះបញ្ជីលើកដំបូង និងបន្តសុពលភាពសម្រាប់សហគ្រាស-ក្រុមហ៊ុន ប្រកបអាជីវកម្មសំណង់ | | | | |
| | - ប្រភេទ 3 (តូច) | 3,000,000 | 20ថ្ងៃ | 3ឆ្នាំ | |
| | - ប្រភេទ 2 (មធ្យម) | 4,000,000 | 20ថ្ងៃ | 3ឆ្នាំ | |
| | - ប្រភេទ 1 (ធំ) | 6,000,000 | 20ថ្ងៃ | 3ឆ្នាំ | |
| 2 | ដំឡើងឋានៈប្រភេទសម្រាប់សហគ្រាស-ក្រុមហ៊ុន ប្រកបអាជីវកម្មសំណង់ | | | | |
| | - ប្រភេទ 3 (តូច) ទៅប្រភេទ 2 (មធ្យម) | 4,000,000 | 20ថ្ងៃ | 3ឆ្នាំ | |
| | - ប្រភេទ 2 (មធ្យម) ទៅប្រភេទ 1 (ធំ) | 6,000,000 | 20ថ្ងៃ | 3ឆ្នាំ | |
| 3 | ចុះបញ្ជីលើកដំបូង និងបន្តសុពលភាពសម្រាប់រូបវន្តបុគ្គលសិក្សាគម្រោងប្លង់ | | | | |
| | - ប្រភេទ 3 (តូច) | 800,000 | 20ថ្ងៃ | 3ឆ្នាំ | |
| | - ប្រភេទ 2 (មធ្យម) | 1,200,000 | 20ថ្ងៃ | 3ឆ្នាំ | |
| | - ប្រភេទ 1 (ធំ) | 1,600,000 | 20ថ្ងៃ | 3ឆ្នាំ | |

| ល.រ | បរិយាយ | តម្លៃសេវា (ជារៀល) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| 4 | ដំឡើងឋានៈកំរិតសម្រាប់រូបវន្តបុគ្គលសិក្សាគម្រោងប្លង់ | | | | |
| | - កំរិតទី 3(តូច) - ទៅកំរិតទី 2(មធ្យម) | 1,200,000 | 20ថ្ងៃ | 3ឆ្នាំ | |
| | - កំរិតទី 2(មធ្យម) - ទៅកំរិតទី 1(ធំ) | 1,600,000 | 20ថ្ងៃ | 3ឆ្នាំ | |
| IV-**ការថតចម្លងឯកសារប្លង់ និងផែនទី** (**តាមការស្នើសុំ**) | | | | | |
| 1 | ឯកសារស្នើសុំសាងសង់ (ក្នុង 1ច្បាប់) | 40,000 | | | |
| 2 | ប្លង់ស្ថាបត្យកម្ម ឬប្លង់គ្រឿងផ្គុំសំណង់ (ក្នុង 1ច្បាប់) | 400,000 | | | |
| 3 | ផែនទី ទំហំ A-4 (ក្នុង 1សន្លឹក) | 1,000 | | | |
| 4 | ផែនទី ទំហំ A-3 (ក្នុង 1សន្លឹក) | 5,000 | | | |
| 5 | ផែនទី ទំហំ A-2 (ក្នុង 1សន្លឹក) | 10,000 | | | |
| 6 | ផែនទី ទំហំ A-1 (ក្នុង 1សន្លឹក) | 15,000 | | | |
| 7 | ផែនទី ទំហំ A-0 (ក្នុង 1សន្លឹក) | 20,000 | | | |
| V-**សេវាពិគ្រោះយោបល់លើផ្នែកច្បាប់ និងបច្ចេកទេស** (**តាមការស្នើសុំ**) | | | | | |
| 1 | នៅថ្នាក់ជាតិ (ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ -ការិយាល័យនៃលេខាធិការដ្ឋានច្រកចេញ-ចូល តែមួយ) | | | | |
| | - លើការងារទាក់ទងទៅនឹងដីធ្លី និងសំណង់ទូទៅ (សម្រាប់មួយករណី) | 100,000 | | | |
| | - លើការងារទាក់ទងទៅនឹងតំបន់សេដ្ឋកិច្ចពិសេស ការអភិវឌ្ឍន៍កោះ ឆ្នេរ បុរី ដីសម្បទានសេដ្ឋកិច្ច និងអគារខ្ពស់ៗ (សម្រាប់មួយករណី) | 2,000,000 | | | |
| 2 | នៅថ្នាក់ក្រោមជាតិ (មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត) | | | | |
| | - លើការងារទាក់ទងទៅនឹងដីធ្លី និងសំណង់ទូទៅ (សម្រាប់មួយករណី) | 80,000 | | | |